# ដំណើររឿងរបស់ អាមែនដា ស្ម៊ីធ នៅឯ ហនស៍ មីល្ល



ថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៨៣៨ ពួកមនុស្សកំណាចបានវាយប្រហារលំនៅដ្ឋានរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយដែលត្រូវបានស្គាល់ថា ហនស៍ មីល្ល ពួកមនុស្សកំណាចបានបាញ់បុរស និងក្មេងប្រុសដែលចូលទៅហាងជាងដែកដើម្បីលាក់ខ្លួន និងដើម្បីការពារប្រជាជនរបស់ពួកគេ ។ ពួកបរិសុទ្ធថ្ងៃចុងក្រោយចំនួនដប់ប្រាំពីរនាក់ត្រូវបានសម្លាប់នៅក្នុងការវាយប្រហារនេះ ហើយរងរបួសលើសពីដប់ពីរនាក់ ។

ក្នុងចំណោមអ្នករងរបួសមានក្មេងឈ្មោះ អាលម៉ា ស្មីធ អាយុប្រាំមួយឆ្នាំ ដែលសន្លាក់ឆ្អឹងត្រគាកទាំងមូលបានខូចបង់បន្ទាប់ពីគេបាញ់គាត់ ។ អាមែនដា បាណាស ស្មីធ ម្តាយរបស់អាលម៉ា មានការខកចិត្តជាខ្លាំងនៅពេលគាត់បានរកឃើញអាលម៉ា ។ នាងក៏បានទួញសោកចំពោះស្វាមីរបស់នាង និងកូនប្រុសអាយុ ១០ ឆ្នាំរបស់នាងដែលទាំងពីរនាក់ត្រូវបានសម្លាប់នៅក្នុងការវាយប្រហារនេះ ។

ដោយគ្មាននរណាម្នាក់អាចជួយនាងបាន អាមែនដាបានប្រមូលកូនដែលនៅសល់របស់នាងជាមួយគ្នា ហើយបានអធិស្ឋានទូលសុំការណែនាំ ។ នាងបានអធិស្ឋានថា « ឱ ព្រះវរបិតាសួគ៌នៃទូលបង្គំ ទ្រង់បានទតឃើញកូនប្រុសមានរបួសដ៏កំសត់របស់ទូលបង្គំ ហើយក៏បានជ្រាបដឹងពីការឆ្លងកាត់របស់ទូលបង្គំដែរ ។ ឱ ! ព្រះវរបិតាសួគ៌ សូមដឹកនាំទូលបង្គំឲ្យដឹងអ្វីដែលត្រូវធ្វើផងចុះ » ។

នៅពេលដែលអាមែនដាបានបញ្ចប់ការអធិស្ឋានរបស់នាង នាងបានឮសំឡេងមួយដែលប្រាប់នាងឲ្យលាយផេះជាមួយទឹក ។ នាងបានប្រើដំណោះស្រាយនេះដើម្បីលាងរបួសរបស់អាលម៉ា រហូតដល់របួសបានស្អាត ។ បន្ទាប់មក អាមែនដាមានអារម្មណ៍ថាបានបំផុសគំនិតឲ្យយកឫសដើមអែម ហើយកិនវាឲ្យហ្មត់ ។ នាងបានយកកំហាប់នោះដាក់លើមុខរបួសរបស់អាលម៉ា ហើយរុំនឹងក្រណាត់ ។

« ឥឡូវនេះកូនគេងអ៊ីចឹងហើយ កុំរើទៅណា » នាងបានប្រាប់កូនប្រុសរបស់នាងថា « ព្រះអម្ចាស់នឹងប្រទានត្រគាកថ្មីឲ្យកូន » ។

របួសរបស់អាលម៉ាបានរារាំង អាមែនដា និងគ្រួសាររបស់នាងពីការជម្លៀសចេញបន្ទាប់ពីការវាយប្រហារនេះ ។ នៅប៉ុន្មានសប្តាហ៍កន្លងទៅ ពួកមនុស្សកំណាចបានកំណត់ពេលវេលាឲ្យនាង និងពួកបរិសុទ្ធផ្សេងទៀតដែលនៅសល់ឲ្យចាកចេញទៅ ។ ការភ័យខ្លាចរបស់ អាមែនដា កាន់តែមានខ្លាំងឡើងនៅពេលថ្ងៃកំណត់បានមកដល់ ។ នាងបានពួននៅក្នុងគុម្ពពោត ដើម្បីនាងអាចអធិស្ឋានចេញសំឡេង ដោយមិនត្រូវបានគេឮ ។ បន្ទាប់មក នាងបានឮសំឡេងមួយដែលនិយាយពាក្យទាំងនេះឡើងវិញ ៖

*ព្រលឹងណាដែលពឹងផ្អែកទៅលើព្រះយេស៊ូវ*

*យើងមិនព្រម យើងមិនអាចបោះចោលឲ្យសត្រូវ*

*សូម្បីតែពួកនរកចង់បានព្រលឹងអ្នក*

*យើងនឹងគ្មានថ្ងៃបោះបង់ . . . យើងនឹងគ្មានថ្ងៃបោះបង់ !*

ពាក្យពេចន៍ទាំងនេះចេញមកពីទំនុកតម្កើង « គ្រឹះដ៏មាំមួន » ( *ទំនុកតម្កើង* ល.រ. ៣៧ ) បានជួយ អាមែនដា ទទួលកម្លាំង និងសេចក្តីក្លាហានថ្មី ។

បន្ទាប់ពីអាមែនដាបាននៅខាងក្រៅមិនយូរប៉ុន្មាន នាងបានឮកូនៗរបស់នាងស្រែកនៅក្នុងផ្ទះរបស់នាង ។ នាងបានប្រញាប់រត់ទៅផ្ទះ ហើយបានឃើញអាលម៉ារត់ជុំវិញបន្ទប់ ។ គាត់បានស្រែកថា « ម៉ែ កូនជាហើយ កូនជាហើយ ! » មិនយូរប៉ុន្មាន អាមែនដា និងកូនៗរបស់នាងបានចាកចេញពី ហនស៍ មីល្ល ។

( បានដកស្រង់ និងសង្ខេបចេញពី *Saints* ១:៣៤៧–៣៥០, ៣៥៣–៣៥៥, ៣៧៨–៣៧៩ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© by Intellectual Reserve, Inc. All rights reserved. PD80007812_258_413-1